# មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## សន្ទនយុត្តិធម៌៖ អំពីប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

### *សំណួររបស់ប្រិយមិត្តអ្នកស្តាប់*
### *ឆ្លើយដោយ លោក វ៉េនឌល ឌឹហ្គាល់តូ*
### *ប្រែសម្រួលជាភាសាខ្មែរដោយ ម៉ែន ពិចិត្រ*

*១. ហេតុអ្វីបានជាខ្មែរក្រហមបង្អត់បាយប្រជាជនខ្លួនឯង នៅពេលដែលផលដំណាំមានច្រើន? តើផលដំណាំទាំងនោះត្រូវបានខ្មែរក្រហមដឹកជញ្ជូនទៅណា?*

- *<u>ចម្លើយ</u>៖ ទីមួយ ខ្មែរក្រហមមានគម្រោងផលិតស្រូវឲ្យបានច្រើន ពោលគឺ ៣តោនក្នុង ១ហិចតា ។ ប៉ុន្តែ ទិន្នផលនេះមិនធ្លាប់ទទួលបានជោគជ័យនោះទេ នៅពេលដែលខ្មែរក្រហមកាន់អំណាច ។ ទីពីរ ផែនការសេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្មជឿនលឿន តាមរយៈការលក់ស្រូវទៅកាន់ទីផ្សារអន្តរជាតិ ដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់អនុវត្តផែនការរបស់ខ្លួន ។ កត្តាទាំងអស់នេះ បានបង្កជាសម្ពាធយ៉ាងខ្លាំងដល់កម្មាភិបាលថ្នាក់ក្រោមតាមតំបន់ ដោយធ្វើយ៉ាងណាផ្តល់នូវទិន្នផលស្រូវឲ្យបានគ្រប់តាមផែនការកំណត់ របស់ថ្នាក់ដឹកនាំមជ្ឈិម ដើម្បីផ្គត់ផ្គង់ដល់យោធាខ្មែរក្រហម និងលក់ទៅប្រទេសដទៃ សម្រាប់ដោះដូរជាប្រាក់កាស និងទំនិញដែលខ្មែរក្រហមមិនអាចផលិតបាន ។*

*២. ហេតុអ្វីបានជាខ្មែរក្រហមឲ្យប្រជាជនធ្វើការធ្ងន់?*

- *<u>ចម្លើយ</u>៖ ខ្មែរក្រហមបានថ្លែងថា គោលនយោបាយរបស់ខ្លួនគឺ រស់នៅឯករាជ្យម្ចាស់ការ នេះមានន័យថា មិនមានជំនួយបរទេសនោះទេ ។ ខ្មែរក្រហមក៏ មានគម្រោងធ្វើឲ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខ "មហាលោតផ្លោះ" ដើម្បីក្លាយជាប្រទេសសង្គមនិយមមួយដ៏រីកចម្រើន និង ធ្វើឲ្យប្រទេសកម្ពុជាមានការរីកលូតលាស់ជាងប្រទេសសង្គមនិយមដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាម ជាដើម ។ ដោយសារតែ ខ្មែរក្រហមពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មប្រជាជន ដើម្បីសម្រេចឲ្យផែនការរបស់ខ្លួន ជាលទ្ធផល ប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងច្រើនម៉ោង ។*

*៣. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង?*

- *<u>ចម្លើយ</u>៖ វាមានកត្តាជាច្រើនដែលបានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងទ្រង់ទ្រាយធំ ។ កត្តាទាំងនោះ រួមមាន ការកាប់សម្លាប់ លក្ខខណ្ឌរស់នៅ និងការបង្អត់អាហារ ។ ខ្មែរក្រហមមាន*

*បំណងប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយមមួយដ៏បរិសុទ្ធ ។ ខ្មែរក្រហមយល់ឃើញថា ខ្លួនមានសត្រូវជាច្រើន ទាំងជនជាតិខ្មែរ និងជនជាតិបរទេស ដែលធ្វើការរារាំងផែនការបដិវត្តន៍របស់ខ្លួន ។ ជាលទ្ធផល ខ្មែរក្រហមមានការភ័យខ្លាច និងព្រួយបារម្ភកាន់តែខ្លាំងឡើងៗចំពោះបញ្ហានេះ ។ មេដឹកនាំខ្មែរក្រហមក៏បានស្តីបន្ទោសទៅលើខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលបានធ្វើឲ្យផែនការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតារបស់ខ្លួនបរាជ័យ ។ ដូច្នេះនៅតំបន់ណាដែលមិនអាចបំពេញតាមផែនការរបស់ខ្មែរក្រហមបាន ខ្មែរក្រហមចាប់ផ្តើមធ្វើការបោសសំអាតតំបន់នោះដោយអំពើហិង្សា ។ ដោយសារតែ មានការប្រើអំពើហិង្សា និងលក្ខខណ្ឌរស់នៅមិនសមរម្យ កត្តាទាំងអស់នេះបានបង្កឲ្យការសម្លាប់ប្រជាជនក្នុងលក្ខណៈទ្រង់ទ្រាយធំ ។*

៨. *ហេតុអ្វីបានជាខ្មែរក្រហមបំបែកគ្រួសារមិនឲ្យរស់នៅជុំគ្នា?*

- <u>*ចម្លើយ*</u>*៖ មេដឹកនាំខ្មែរក្រហមដឹងថា គ្រួសារមានសារៈសំខាន់ និងទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសង្គមខ្មែរ ។ មេដឹកនាំខ្មែរក្រហមគិតថា ប្រជាជនកម្ពុជាគ្រប់រូបគួរតែស្មោះត្រង់នឹងបដិវត្តន៍របស់ខ្លួន ជាងសមាជិកគ្រួសារ ។ មេដឹកនាំខ្មែរក្រហម ក៏ប្រមើលមើលឃើញថាគ្រួសារ គឺជាបញ្ហាប្រឈមមួយ ចំពោះផែនការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជារដ្ឋសង្គមនិយមមួយដ៏ស្អាតស្អំ ។ ដូច្នេះ ដើម្បីសម្រេចផែនការនេះ ខ្មែរក្រហមមិនបានគិតពីទំនាក់ទំនងគ្រួសារនៅក្នុងសង្គមកម្ពុជានោះទេ ។ ហេតុផលមួយផ្សេងទៀតចំពោះការបំបែកបំបាក់គ្រួសារដោយសារតែ ខ្មែរក្រហមត្រូវការកម្លាំងពលកម្មដើម្បីបំពេញការងារទៅតាមគោលដៅបដិវត្តន៍ ដូច្នេះ ប្រជាជនត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់តំបន់ផ្សេងៗពីគ្នា ។*

៩. *ហេតុអ្វីបានជាមិនមានប្រជាជនណាម្នាក់ធ្វើការប៉ះបោរនឹងខ្មែរក្រហម?*

- <u>*ចម្លើយ*</u>*៖ បានជាប្រជាជនមិនធ្វើការប៉ះបោរនឹងខ្មែរក្រហមដោយសារតែ៖ ទីមួយ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទៅកាន់តំបន់ផ្សេងៗគ្នា ដែលធ្វើឲ្យប្រជាជនមានការពិបាកក្នុងការបង្កើតក្រុម ដើម្បីធ្វើការប្រឆាំងតបតនឹងយោធាខ្មែរក្រហម ។ ទីពីរ នៅតាមទីជនបទ ប្រជាជនខ្មែរត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា ។ ប្រសិនបើប្រជាជនណាម្នាក់ត្រូវបានចោទប្រកាន់ថាបាន និយាយអ្វីមិនល្អប៉ះពាល់ដល់បដិវត្តន៍ ប្រជាជនរូបនោះនឹងត្រូវខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងអាចត្រូវបានខ្មែរក្រហមសម្លាប់ ។ កត្តានេះបានបង្កឲ្យមានភាពលំបាកកាន់តែខ្លាំងឡើងសម្រាប់ប្រជាជនកម្ពុជា ដើម្បីរៀបចំក្រុមប៉ះបោរប្រឆាំងនឹងខ្មែរក្រហម ។ ទីបី ដោយសារតែ ប្រជាជនកម្ពុជា ត្រូវបានខ្មែរក្រហម*

បន្ទុំឲ្យធ្វើការធ្ងន់ស្ទើរតែស្លាប់ និងការបង្អត់អាហារ ។ ដូច្នេះ ប្រជាជនកម្ពុជាពុំមាន កម្លាំងគ្រប់គ្រាន់ក្នុងការប្រឆាំងតបតនឹងខ្មែរក្រហមនោះទេ ។ ទីបួន កម្មាភិបាលខ្មែរក្រហមគ្រប់ភូមិស្រុកមានអាវុធកាន់គ្រប់ដៃ ចំណែកឯប្រជាជនកម្ពុជាពុំមានអាវុធអ្វីអាចធ្វើវាយបកនឹងខ្មែរក្រហមបាននោះទេ ។ នៅក្នុងរបបខ្មែរក្រហម ក៏ធ្លាប់មានព្រឹត្តិការណ៍ប៉ះបោរកើតឡើងដែរ ។ ព្រឹត្តិការណ៍កើតឡើងនៅក្នុងភូមិមួយ នៅពេលដែលមេដឹកនាំខ្មែរអ៊ីស្លាម នៅក្នុងភូមិមួយត្រូវបានខ្មែរក្រហមសម្លាប់ និងការប្រតិបត្តិសាសនា និងប្រពៃណីត្រូវបានលុបបំបាត់ ។ ប៉ុន្តែការប៉ះបោររបស់ប្រជាជនខ្មែរអ៊ីស្លាមនៅក្នុងភូមិនោះ ត្រូវបានខ្មែរក្រហមបង្ក្រាបទៅវិញ នៅពេលដែលប្រជាជនខ្មែរអ៊ីស្លាមទាំងនោះពុំមានអាវុធអ្វី ក្រៅពីកាំបិត និងដាវ ។ បន្ទាប់មកប្រជាជនខ្មែរអ៊ីស្លាមដែលបានចូលរួមប៉ះបោរ ត្រូវបានខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ។

៦. តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬទេ?

- ចម្លើយៈ បច្ចុប្បន្ន តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានចេញសាលក្រមទាក់ទងនឹងជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាមេគុកទួលស្លែង ។ ស្របពេលនឹងគ្នានេះដែរ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំពុងបន្តដំណើរការកាត់ក្តីទៅលើជនជាប់ចោទពីររូបផ្សេងទៀត ដែលជាអតីតមេដឹកនាំខ្មែរក្រហម រួមមាន នួន ជា និង ខៀវ សំផន ។ បុគ្គល ម្នាក់ៗមានការយល់ឃើញខុសគ្នាទៅលើអត្ថន័យនៃពាក្យ “យុត្តិធម៌” ហើយថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬយ៉ាងណា នោះជាការយល់ឃើញរបស់ជនរងគ្រោះម្នាក់ៗ ។

សំណួរផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយៈ

- អ៊ួច សុខសិរីមន្នីកា, ខេត្តព្រះវិហារ
- ភត្រា, ខេត្តព្រះវិហារ
- សុភា, ខេត្តព្រះវិហារ

**DC-Cam Voices of Genocide Radio Program**
**Listener Questions**
**Answers by Randle DeFalco**

1. Why did the Khmer Rouge starve their people when they had produced a lot of crops? Where had those crops been transported to?
    - First, the Khmer Rouge planned to produce incredibly large crops of rice while in power, but these plans to produce three tons of rice per hectare were never successful while the Khmer Rouge were in power, so rice crops were not nearly as large as planned. That being said, there is evidence suggesting that, while not massive, a significant rice crop was harvested each year during the Khmer Rouge period. Second, the Khmer Rouge's economic plan was to independently transform Cambodia into a modern industrial country by selling rice on the international market to gain income to fund the regime's goals. Thus, there was a large amount of pressure on local leaders to provide the Khmer Rouge central leadership with a lot of rice to support both the Khmer Rouge military and to sell to other countries in exchange for money and goods that could not be produced in Cambodia. Available evidence suggests that China was the recipient of most of the rice shipped out of Cambodia during the Khmer Rouge period.

2. Why did the Khmer Rouge put their people to hard work?
    - The Khmer Rouge stated that the regime's official policy was one of "independence self-mastery" which meant that no foreign aid or assistance would be accepted. The regime also had plans for Cambodia to take a "super great leap forward" towards becoming a modern socialist country and wanted to achieve revolutionary goals at a faster rate than previous socialist revolutions, especially those in China and Vietnam. As a result, the Khmer Rouge leadership sought to rely on human labour alone to achieve massive agricultural and infrastructure projects, resulting in hard labour and extreme hours of work.

3. Why did the Khmer Rouge kill their people?
    - This is a difficult and complex question that has been considered by many scholars. The answer is that there were many factors that combined to create a situation where people were killed in very large numbers through both executions and living conditions, including famine. Generally, the Khmer Rouge leaders wanted to rapidly achieve a pure socialist revolution and believed that there were enemy agents, both foreign and within Cambodia, who were working to undermine the regime's revolutionary plans. As a result, over time the leaders became more and more paranoid. Eventually, the leaders blamed all of their failed plans, for example the plan to achieve three tons of rice per hectare, on acts of sabotage by hidden "internal enemies." Thus, whenever an area of the country failed to live up to the expectations of the Khmer Rouge leaders, this area would likely be violently purged. In this way violence and living conditions both spiraled out of control and resulted in so much killing.

4. Why did the Khmer Rouge separate people from their family members?
    - The Khmer Rouge leaders knew that family ties are very strong in Cambodia and thought that people should be loyal to the revolution more than to their family members. These leaders saw family social structures as competing with their plan to turn Cambodia into a pure socialist state and therefore did not worry about separating people from their families. Another reason for these separations was the fact that the Khmer Rouge assigned people to be sent to wherever the revolution needed more human labour and no thought was given to keeping families together when assigning people to areas of the country.

5. Why didn't people rebel against the Khmer Rouge?
    - It is impossible to know why people did not rebel against the Khmer Rouge, but there are likely several reasons why they did not. First, the Khmer Rouge came into power quickly and immediately spread people throughout the countryside, making it difficult for people to form groups to oppose the powerful Khmer Rouge military. Second, even on the local level, people were constantly watched by Khmer Rouge cadres and if they were caught saying anything bad about the revolution, they could be put in prison, beaten or even executed. This made it even harder for people to organize any rebellion. Third, people were overworked to the point of near death during the Khmer Rouge period. Because people were so weakened from overwork and lack of food, it is likely that they were simply too exhausted and weak to fight back, but focused all of their energy on simply surviving each day. Fourth, there were armed Khmer Rouge cadres throughout the countryside and local people did not have the weapons to effectively fight cadres who had guns and other weapons. In one village, a group of Cham Muslims did rebel against the Khmer Rouge after some of their local leaders were executed and they were banned from praying or otherwise practicing their religion. However, this rebellion was doomed to failure because the rebels mostly only had swords, while the Khmer Rouge had guns and other weapons. After the rebellion, almost everyone who had fought back was put in prison, tortured and executed.

6. Has the Khmer Rouge Tribunal brought justice to the Khmer Rouge victims?
    - As of now the Khmer Rouge Tribunal has entered one verdict against Kaing Guek Eav alias Duch and is in the process of the trial of Nuon Chea and Khieu Samphan, former Khmer Rouge leaders. The meaning of justice is a very personal thing however, and it is up to each survivor of the Khmer Rouge period and indeed, every Cambodian citizen, to decide for themselves whether they are satisfied with the work of the Tribunal.

Questions received from:

- Ouch Sokserey Monika, Preah Vihear Province
- Pheaktra, Preah Vihear Province
- Sophea, Preah Vihear Province